## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៤២៤,២៤៦ ដុល្លារអាមេរិកសម្រាប់ គម្រោងពង្រីកអគារវះកាត់ក្នុងមន្ទីរពេទ្យកុមារជាតិ



ក្រោមគ្រោងការណ៍នៃជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ៤២៤,២៤៦ដុល្លារអាមេរិកដល់មូលនិធិសម្រាប់ការអភិវឌ្ឍន៍ និង ជំនួយសង្គ្រោះអន្តរជាតិ(FIDR)សម្រាប់គម្រោងពង្រីកអគារវះកាត់ក្នុងមន្ទីរពេទ្យកុមារជាតិ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានាថ្ងៃនេះដោយ ឯកឧត្តម គូរ៉ូគី ម៉ាសាហ្វ៊ូមី ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង កញ្ញា អាគេមិ តាកាហាហ្ស៊ិ (TAKAHASHI Akemi) នាយិកាFIDR នៅស្ថានទូតជប៉ុន។

ដើម្បីបង្កើនគុណភាពនៃសេវាវះកាត់កុមារ និង កម្រិតនៃការបណ្តុះបណ្តាលផ្នែកសុខាភិបាលក្នុងមន្ទីរពេទ្យកុមារជាតិ FIDRនឹងអនុវត្តគម្រោងពង្រីកអគារវះកាត់ក្នុងមន្ទីរពេទ្យកុមារជាតិដោយធ្វើការសាងសង់បន្ទប់វះកាត់ថ្មីមួយ បន្ទប់បណ្តុះបណ្តាលមួយ និង បន្ទប់ថែទាំសម្រាប់អ្នកជំងឺធ្ងន់មួយ ព្រមទាំងធ្វើការជួសជុលអគារ និងកែលម្អប្រព័ន្ធទឹកនិងហ្គាសក្នុងអគារផងដែរ។ FIDRក៏នឹងតំឡើងឧបករណ៍បរិក្ខារពេទ្យ ព្រមទាំងផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាលក្នុងមន្ទីរពេទ្យកុមារជាតិ ក៏ដូចជាមន្ទីរពេទ្យដែលនៅខេត្តជិតៗផងដែរ។ នៅពេលដែលគម្រោងនេះត្រូវបានបញ្ចប់ កុមារដែលត្រូវទទួលការវះកាត់ប្រមាណ១០,០០០នាក់ក្នុងមន្ទីរពេទ្យកុមារជាតិ ក៏ដូចជាមន្ទីរពេទ្យដែលនៅខេត្តជិតខាងនឹងទទួលបានសេវាសុខាភិបាលដែលមានគុណភាពប្រសើរជាងមុនដោយសារវគ្គបណ្តុះបណ្តាល ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈបរិក្ខារដែលនឹងត្រូវអនុវត្តក្នុងគម្រោងដោយFIDR។



កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង១៧.៥លានដុល្លាអាមេរិកដល់គម្រោងចំនួន៦៨គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល និង សកម្មភាពបោសសំអាតមីន។ គម្រោងរបស់មូលនិធិសម្រាប់ការអភិវឌ្ឍន៍ និង ជំនួយសង្គ្រោះអន្តរជាតិនេះគឺជាគម្រោងទី៤តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១២របស់ប្រទេសជប៉ុន (មេសា២០១២ដល់មិនា២០១៣)។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែលៈ eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*